ការចាក់ថ្នាំបង្ការរោគសម្រាប់បុគ្គលិកនឹងចាប់ផ្តើមក្នុងពេលឆាប់ៗខាងមុខ ខណៈដែលគម្រោងរៀបចំបើកសាលាកំពុងតែបន្តធ្វើ

រដ្ឋកាលីហ្វ័រនីញ៉ាប៉ែកខាងត្បូងចាប់ផ្តើមឆ្នាំ២០២១ជាមួយករណីកូវីឌយ៉ាងខ្ពស់ជាងពេលណាទាំងអស់ហើយប្រព័ន្ធថែទាំសុខភាពក្នុងតំបន់បានប្រតិបត្តិហួសពីសមត្ថភាពនូវកម្រិតអាសន្នមួយ។ ប៉ុន្តែការអភិវឌ្ឍដ៏មានសង្ឃឹមមួយនៅក្នុងការប្រយុទ្ធតទល់ជាមួយការរាតត្បាតនេះគឺការចាប់ផ្តើមមាននូវថ្នាំបង្ការរោគកូវីឌ។ ក្រសួងអប់រំឡុងប៊ីចបន្តធ្វើទំនាក់ទំនងយ៉ាងជាប់លាប់ជាមួយមន្ត្រីសុខភាពក្នុងរដ្ឋនិងក្រុងអំពីគម្រោងនៃការបើកសាលារៀនវិញសម្រាប់ការរៀនសូត្រធម្មតា ហើយនិងការចែកចាយចាក់ថ្នាំបង្ការរោគដល់បុគ្គលិករបស់ក្រសួងអប់រំ។

អ្នកអប់រំទូទាំងប្រទេសត្រូវបានផ្តល់អាទិភាពសម្រាប់ទទួលការចាក់ថ្នាំបង្ការរោគ។ ចាប់ផ្តើមនៅថ្ងៃទី២៥មករា បុគ្គលិកនិងគ្រូបង្រៀនរបស់ក្រសួងអប់រំឡុងប៊ីចនឹងអាចទទួលដូសទីមួយនៃការចាក់ថ្នាំបង្ការរោគ ម៉ូឌើណា នៅក្នុងឡុងប៊ីច។ បន្ទាប់មកប្រហែលជាមួយខែក្រោយមក ពួកគេនឹងទទួលបានការចាក់ថ្នាំបង្ការរោគដូសទីពីរ។ ក្រសួងអប់រំមានការពេញចិត្តជាខ្លាំងចំពោះភាពជាដៃគូជាមួយទីក្រុងឡុងប៊ីចនិងក្រសួងសុខាភិបាលក្រុងឡុងប៊ីច។ ភាពជាដៃគូនេះអនុញ្ញាតឱ្យក្រសួងអប់រំបង្កើតផែនការណ៍ជាសហការហើយចាប់អនុវត្តនូវផែនការណ៍ទាំងនោះឱ្យបានយ៉ាងឆាប់ៗ។

ខណៈដែលការចាក់ថ្នាំបង្ការរោគដល់មនុស្សឱ្យបានគ្រប់គ្រាន់នឹងចំណាយពេលវេលា ការខ្នះខ្នែងគឺជាជំហានដ៏សំខាន់ ឆ្ពោះទៅកាន់ការបើកសាលារៀនវិញ សម្រាប់ការសិក្សាធម្មតា ឱ្យបានឆាប់ដែលអាចធ្វើទៅបាន។

ដូចដែលក្រសួងអប់រំឡុងប៊ីចបានជូនដំណឹងកន្លងមក ចៅហ្វាយខេត្តរដ្ឋកាលីហ្វ័រនីញ៉ា Gavin Newsom បានប្រកាសគម្រោងសាលារៀនមានសុវត្ថិភាពសម្រាប់អ្នករាល់គ្នាមួយ កាលពីថ្ងៃទី៣០ខែធ្នូ ដែលបន្ថែមទៅលើវិធានការដែលមានរួចស្រេចរបស់ក្រសួងអប់រំ  សម្រាប់ការបើកសាលារៀនឱ្យមានសុវត្ថិភាពសម្រាប់ការសិក្សាជាធម្មតា សម្រាប់សិស្សសាលាបឋមសិក្សា។ ដោយសារក្រសួងអប់រំឡុងប៊ីចបានរៀបចំគ្រោងការបើកទ្វារសាលាសម្រាប់ការសិក្សាជាធម្មតាវិញអស់រយៈពេលជាច្រើនខែកន្លងមកហើយ ក្រសួងអប់រំបានដោះស្រាយកត្តាផ្សេងៗមួយចំនួននៅក្នុងគម្រោងរួចមកហើយដែរ។ ប៉ុន្តែក្រសួងអប់រំ LBUSD ក៏កំពុងគិតគូរកមើលសក្តានុពលបន្ថែមការធ្វើតេស្តរោគកូវីឌនៅតាមសាលារៀនសម្រាប់បុគ្គលិកមនុស្សពេញវ័យ និងសិស្សានុសិស្ស ដែលជាតម្រូវការមួយនៃផែនការ។ នៅក្នុងការខ្នះខ្នែងដើម្បីបំពេញដល់សេចក្តីចាំបាច់ផ្សេងៗរបស់សិស្ស អគ្គនាយកក្រសួងអប់រំ LBUSD Jill Baker បានចូលរួមជាមួយអគ្គនាយកដទៃទៀតពីក្រសួងអប់រំធំៗនៅក្នុងរដ្ឋកាលីហ្វ័រនីញ៉ា  ក្នុងការចែករំលែកនូវភាពលំបាកផ្សេងៗរបស់សាលារៀនជាមួយរដ្ឋ។ LBUSD បានបន្តពីគ្រោះជាមួយសមាគមគ្រូបង្រៀនដើម្បីគិតរកមើលរបៀបបិតបេរសម្រាប់បើកសាលាបង្រៀនជាធម្មតាវិញ។

ដែលជាចំណែកមួយនៃផែនការរបស់ក្រសួងអប់រំ ក្នុងសប្តាហ៍នេះ មាតាបិតានិងអាណាព្យាបាលសិស្សសាលាបឋមសិក្សាទាំងអស់ បានទទួលព័ត៌មានអំពីការស្ទង់មតិមួយស្តីពីចំណាប់អារម្មណ៍ក្នុងការឱ្យកូនទៅរៀននៅសាលាជាធម្មតាវិញ នៅពេលដែលយើងអនុញ្ញាតឱ្យធ្វើទៅបាន។ លទ្ធផលនៃការស្ទង់មតិនឹងអនុញ្ញាតឱ្យសាលារៀបចំគ្រោងសម្រាប់ទៅថ្ងៃមុខ និងជាពិសេសសម្រាប់ចំនួនសិស្សសាលាបឋមសិក្សាប៉ុន្មានអ្នកដែលអាចវិលត្រឡប់ទៅរៀននៅសាលាជាធម្មតាវិញបាននៅឆ្នាំនេះ។

ទន្ទឹមនឹងនេះ បន្ថែមពីលើការគាំទ្រដល់ការសិក្សាតាមអនឡាញ ក្រុមមួយបានកំពុងរៀបចំការគាំទ្រផ្លូវចិត្តនិងអារម្មណ៍ និងសេវាអន្តរាគមការសិក្សាដែលនឹងផ្តល់ឱ្យសិស្សនៅក្នុងរដូវផ្ការីកនិងរដូវក្តៅនៃឆ្នាំនេះនិងនៅក្នុងរដូវឈើជ្រុះស្លឹកផងដែរ។ ក្រសួងអប់រំ ដឹងថាសិស្សនឹងត្រូវការការគាំទ្រគ្រប់យ៉ាងនៅក្នុងសប្តាហ៍ខាងមុខនេះហើយប្តេជ្ញាជួយសិស្សឱ្យឆ្លងកាត់ភាពលំបាកទាំងឡាយដែលពួកគេជាច្រើនកំពុងប្រឈមមុខនៅក្នុងពេលរាតត្បាតជាសាកលនេះ។ យើងសូមថ្លែងអំណរគុណដល់ការគាំទ្រពីអ្នករាល់គ្នានៅក្នុងសហគមន៍ក្រសួងអប់រំ LBUSD នៅក្នុងគ្រាដ៏លំបាកនេះ។